**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០១១ សហវ

ថ្ងៃសុក្រ ៦ រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨

# សារាចរណែនាំ
## ស្តីពី
## ការអនុវត្តនីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិលនិងមន្ត្រីសាធារណៈផ្សេងទៀត

**យោង÷** សារាចរលេខ ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត។

ដើម្បីអនុវត្តនីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀតឱ្យមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញសារាចរណែនាំអំពីគោលការណ៍សំខាន់ៗ និងនីតិវិធីនៃការបើកផ្តល់ ដូចខាងក្រោម÷

**១.ការផ្ទេរសិទ្ធិក្នុងការចុះហត្ថលេខាលើអាណត្តិបើកប្រាក់÷**

ក.ថ្នាក់កណ្តាល÷

-រដ្ឋមន្ត្រី ប្រធានស្ថាប័ន ក្នុងនាមជាអាណាប័កដើមខ្សែ និងប្រធានអង្គភាពរដ្ឋបាលថ្នាក់ជាតិ ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ពិនិត្យ និងចុះហត្ថលេខាដោយផ្ទាល់លើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត និងអាណត្តិបើកប្រាក់ប្រាក់កម្រៃប្រចាំខែរបស់បុគ្គលិកជាប់កិច្ចសន្យា។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពរដ្ឋបាលថ្នាក់ជាតិ អាចធ្វើប្រតិភូកម្មដល់មន្ត្រីក្រោមឱវាទ ពិនិត្យនិងចុះហត្ថលេខា ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិលើអាណត្តិបើកប្រាក់បៀវត្ស

-អាណត្តិបើកប្រាក់បៀវត្ស ដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ក និងទទួលបានទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន ត្រូវបញ្ជូនទៅរតនាគារថ្នាក់កណ្តាល យ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១នៃខែដែលត្រូវបើកផ្តល់បៀវត្ស។ ក្នុងករណីពុំទាន់មានមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំនៅក្រសួង ស្ថាប័ន អាណត្តិបើកប្រាក់បៀវត្ស ដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ករួចហើយ ត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) យ៉ាងយូរត្រឹមថ្ងៃទី១ ក្នុងសប្តាហ៍ទី១នៃខែដែលត្រូវបើកផ្តល់បៀវត្ស ដើម្បីទទួលបានទិដ្ឋាការ រួចត្រូវបញ្ជូនទៅរតនាគារថ្នាក់កណ្តាល យ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១នៃខែដែលត្រូវបើកផ្តល់បៀវត្ស។

**ខ.ថ្នាក់មូលដ្ឋាន÷**

-អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្នុងនាមជាអាណាប័កដើមខ្សែ ពិនិត្យ និងចុះហត្ថលេខា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.

ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ដោយផ្ទាល់ ឬ ប្រគល់សិទ្ធិជូនអភិបាលរង ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់ប្រចាំខែនៃបៀវត្ស សម្រាប់មន្ត្រីរាជការ និងមន្ត្រីសាធារណៈផ្សេងទៀត ប្រាក់កម្រៃសម្រាប់បុគ្គលិកជាប់កិច្ចសន្យា និងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត

-ប្រធានមន្ទីរ ឬ អង្គភាពពាក់ព័ន្ធក្នុងនាមអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រីក្រសួង ឬ ស្ថាប័ន ឬ ប្រធានអង្គភាពពាក់ព័ន្ធ ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់ ឬ ប្រគល់សិទ្ធិដល់អនុប្រធាន ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការ ប្រាក់កម្រៃសម្រាប់បុគ្គលិកជាប់កិច្ចសន្យាបម្រើការងារក្នុងមន្ទីរ ឬ អង្គភាពពាក់ព័ន្ធ

-អភិបាលនៃគណៈអភិបាលក្រុង ស្រុក ក្នុងនាមជាអាណាប័កដើមខ្សែ ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់ ឬ ប្រគល់សិទ្ធិជូនអភិបាលរង ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់ប្រចាំខែនៃបៀវត្សសម្រាប់មន្ត្រីរាជការ មន្ត្រីសាធារណៈផ្សេងទៀត ប្រាក់កម្រៃបុគ្គលិកជាប់កិច្ចសន្យា និងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក

-អភិបាលនៃគណៈអភិបាលខណ្ឌ ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់ ឬ ប្រគល់សិទ្ធិជូនអភិបាលរង ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់ប្រចាំខែនៃបៀវត្សសម្រាប់មន្ត្រីរាជការ មន្ត្រីសាធារណៈផ្សេងទៀត ប្រាក់កម្រៃបុគ្គលិកជាប់កិច្ចសន្យា និងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ក្រុមប្រឹក្សាខណ្ឌ

-អាណត្តិបើកប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែ របស់រដ្ឋបាលរាជធានី ខេត្ត មន្ទីរជំនាញ អង្គភាពពាក់ព័ន្ធ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរត្រឹមថ្ងៃទី១ ក្នុងសប្តាហ៍ទី១នៃខែដែលត្រូវបើកផ្តល់បៀវត្ស រួចបញ្ជូនទៅរតនាគាររាជធានី ខេត្ត យ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១ នៃខែដែលត្រូវបើកផ្តល់បៀវត្ស

-មេឃុំ ក្នុងនាមជាអាណាប័កដើមខ្សែ ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់ ឬ ប្រគល់សិទ្ធិជូនជំទប់ ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់ឧបត្ថម្ភសម្រាប់ក្រុមប្រឹក្សាឃុំ និងប្រាក់កម្រៃប្រចាំខែសម្រាប់បុគ្គលិកជាប់កិច្ចសន្យា។ អាណត្តិបើកប្រាក់បៀវត្សរបស់រដ្ឋបាលឃុំ ត្រូវបានបញ្ជូនទៅរតនាគាររាជធានី ខេត្ត យ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១ នៃខែដែលត្រូវបើកផ្តល់បៀវត្ស

-ចៅសង្កាត់ ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់ ឬ ប្រគល់សិទ្ធិជូនចៅសង្កាត់រង ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់ឧបត្ថម្ភសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រាក់កម្រៃប្រចាំខែសម្រាប់បុគ្គលិកជាប់កិច្ចសន្យា។ អាណត្តិបើកប្រាក់បៀវត្សរបស់រដ្ឋបាលសង្កាត់ ត្រូវបានបញ្ជូនទៅរតនាគាររាជធានី ខេត្ត យ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១ នៃខែដែលត្រូវបើកផ្តល់បៀវត្ស។

**២.ការបើកផ្តល់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ ពីអគ្គនាយកដ្ឋានរតនាគារជាតិ÷**

-បន្ទាប់ពីទទួលបានអាណត្តិបើកប្រាក់ ពីក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមកាលកំណត់ខាងលើ **អគ្គនាយកដ្ឋានរតនាគារជាតិ** (រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត) ត្រូវចាត់ចែងការត្រួតពិនិត្យ និងរៀបចំបើកផ្តល់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ ជូនដល់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានទាន់ពេលវេលានៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ក្នុងនោះ÷ លើកទី១ ឱ្យបានទាន់ក្នុងសប្តាហ៍ទី២ និងលើកទី២ ឱ្យបានទាន់ក្នុងសប្តាហ៍ទី៤។

ក.<u>ករណីអាណត្តិបើកប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ មកដល់រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត ទាន់ពេលវេលាកំណត់:</u>

ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរួសរាន់រៀបចំលិខិតស្នើសុំដោយបែងចែកទឹកប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែជាពីរចំណែកស្មើៗគ្នា គឺសម្រាប់សប្តាហ៍ទី២ និងសប្តាហ៍ទី៤ (មានគំរូភ្ជាប់មកជាមួយ) ភ្ជាប់មកជាមួយអាណត្តិបើកប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ មករតនាគារថ្នាក់កណ្តាលនិងរតនាគាររាជធានីខេត្ត

-ក្រោយពីបានទទួលលិខិតស្នើសុំនិងអាណត្តិបើកប្រាក់របស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ រតនាគារចាត់ចែងត្រួតពិនិត្យ និងបើកផ្តល់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ ជូនក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

ខ.<u>ករណីអាណត្តិបើកប្រាក់បៀវត្សមកដល់រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត មិនទាន់ពេលវេលាកំណត់:</u>

**ខ.១.** នៅរតនាគារថ្នាក់កណ្តាល÷

-ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវប្រគល់ជូនរតនាគារថ្នាក់កណ្តាលនូវតារាងទូទាត់បៀវត្សប្រចាំខែ ដែលផ្តល់ដោយក្រសួងមុខងារសាធារណៈដោយមានភ្ជាប់ជាមួយលិខិតស្នើសុំដោយបែងចែកទឹកប្រាក់បៀវត្ស និងប្រាក់កម្រៃជាពីរចំណែកស្មើៗគ្នា គឺសម្រាប់សប្តាហ៍ទី២ និងសប្តាហ៍ទី៤ (មានគំរូភ្ជាប់មកជាមួយ)។ រតនាគារថ្នាក់កណ្តាល ត្រូវផ្តល់បុរេប្រទានជាសាច់ប្រាក់ដល់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ

-រយៈពេលមួយសប្តាហ៍ក្រោយពីទទួលបានប្រាក់បុរេប្រទាន ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវរៀបចំបោះផ្សាយអាណត្តិទូទាត់ប្រាក់បុរេប្រទានឱ្យបានទាន់ពេលវេលា។ ក្នុងករណីដែលអាណត្តិបើកប្រាក់មកដល់រតនាគារថ្នាក់កណ្តាលក្រោយពីបានទទួលប្រាក់បុរេប្រទាន ក្នុងសប្តាហ៍ទី៣នៃខែដែលត្រូវបើកផ្តល់បៀវត្ស អាណត្តិបើកប្រាក់បៀវត្សនោះ ត្រូវមានកម្មវត្ថុចំណាយដាក់ថា"ទូទាត់បុរេប្រទាន និងបើកផ្តល់បៀវត្ស" ដោយធ្វើការទូទាត់ជម្រះបុរេប្រទានលើបៀវត្សមួយចំណែកដែលបានទទួលបុរេប្រទានក្នុងសប្តាហ៍ទី២ និងធ្វើការបើកផ្តល់បៀវត្សបន្ថែមមួយចំណែកទៀតក្នុងសប្តាហ៍ទី៤។ ប៉ុន្តែបើការបញ្ជូនអាណត្តិបើកប្រាក់យឺតយ៉ាវលើសសប្តាហ៍ទី៤ អាណត្តិបើកប្រាក់បៀវត្សនោះ ត្រូវមានកម្មវត្ថុចំណាយដាក់ថា "ទូទាត់បុរេប្រទាន"។ រតនាគារថ្នាក់កណ្តាលមានភារកិច្ចកែតម្រូវលើអាណត្តិបើកប្រាក់ដោយផ្ទាល់នូវកម្មវត្ថុ "ទូទាត់បុរេប្រទាន និងបើកផ្តល់បៀវត្ស" ឬ "ទូទាត់បុរេប្រទាន" ឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ខ.២.** នៅរតនាគាររាជធានី ខេត្ត÷

-មន្ទីរជំនាញ អង្គភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រគល់ជូនរតនាគាររាជធានី ខេត្ត នូវតារាងទូទាត់បៀវត្សប្រចាំខែ ដែលផ្តល់ដោយមន្ទីរមុខងារសាធារណៈដោយមានភ្ជាប់ជាមួយលិខិតស្នើសុំដោយបែងចែកទឹកប្រាក់បៀវត្ស និងប្រាក់កម្រៃ ជាពីរចំណែកស្មើៗគ្នា គឺសម្រាប់សប្តាហ៍ទី២ និងសប្តាហ៍ទី៤ (មានគំរូភ្ជាប់មកជាមួយ)។ រតនាគាររាជធានី ខេត្ត ត្រូវផ្តល់បុរេប្រទានជាសាច់ប្រាក់ដល់មន្ទីរជំនាញ អង្គភាព និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-ចំពោះប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សានិងប្រាក់កម្រៃរបស់បុគ្គលិកជាប់កិច្ចសន្យានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកតាមតារាងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា និងតារាងប្រាក់កម្រៃបុគ្គលិកជាប់កិច្ចសន្យាដែលបានរៀបចំដោយសាមីអង្គភាព និងយោងតាមលិខិតស្នើសុំដោយបែងចែកទឹកប្រាក់បៀវត្ស និងប្រាក់កម្រៃ ជាពីរចំណែកស្មើៗគ្នា គឺសម្រាប់សប្តាហ៍ទី២ និងសប្តាហ៍ទី៤(មានគំរូភ្ជាប់មកជាមួយ) រតនាគាររាជធានី ខេត្ត ត្រូវផ្តល់បុរេប្រទានជាសាច់ប្រាក់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ

-រយៈពេលមួយសប្តាហ៍ក្រោយពីទទួលបានប្រាក់បុរេប្រទាន មន្ទីរជំនាញ អង្គភាព និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវរៀបចំបោះផ្សាយអាណត្តិទូទាត់ប្រាក់បុរេប្រទានឱ្យបានទាន់ពេលវេលា។ ក្នុងករណីដែលអាណត្តិបើកប្រាក់មកដល់រតនាគាររាជធានី ខេត្ត ក្រោយពីបានទទួលប្រាក់បុរេប្រទាន ក្នុងសប្តាហ៍ទី៣ នៃខែដែលត្រូវបើកផ្តល់បៀវត្ស អាណត្តិបើកប្រាក់បៀវត្សនោះ ត្រូវមានកម្មវត្ថុចំណាយដាក់ថា “ទូទាត់បុរេប្រទាន និងបើកផ្តល់បៀវត្ស” ដោយធ្វើការទូទាត់ជម្រះបុរេប្រទានលើបៀវត្សមួយចំណែកដែលបានទទួលបុរេប្រទានក្នុងសប្តាហ៍ទី២ និងធ្វើការបើកផ្តល់បៀវត្សបន្ថែមមួយចំណែកទៀតក្នុងសប្តាហ៍ទី៤។ ប៉ុន្តែបើការបញ្ជូនអាណត្តិបើកប្រាក់យឺតយ៉ាវលើសសប្តាហ៍ទី៤ អាណត្តិបើកប្រាក់បៀវត្សនោះ ត្រូវមានកម្មវត្ថុចំណាយដាក់ថា “ទូទាត់បុរេប្រទាន”។ រតនាគាររាជធានី ខេត្តមានភារកិច្ចកែតម្រូវលើអាណត្តិបើកប្រាក់ដោយផ្ទាល់នូវកម្មវត្ថុ “ទូទាត់បុរេប្រទាន និងបើកផ្តល់បៀវត្ស” ឬ “ទូទាត់បុរេប្រទាន” ឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

១.៣. <u>បញ្ជាក់:</u>

-ចំនួនទឹកប្រាក់បុរេប្រទានដែលត្រូវបើកផ្តល់ជូនក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាចំនួនទឹកប្រាក់បានកាត់ពន្ធលើបៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែរួច

-ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវគិតគូរជាមុន ដើម្បីធានាថា មានឥណទានគ្រប់គ្រាន់សម្រាប់ការបោះផ្សាយអាណត្តិបើកប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ ឬ មានឥណទានគ្រប់គ្រាន់ដើម្បីអាចបើកប្រាក់បុរេប្រទាន

-រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវគិតគូរជាមុន ដើម្បីធានាថា មានឥណទានគ្រប់គ្រាន់ និងសមតុល្យគណនីប្រាក់បញ្ញើចវិកាសម្រាប់បោះផ្សាយអាណត្តិបើកប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ ឬ មានឥណទានគ្រប់គ្រាន់ដើម្បីអាចបើកប្រាក់បុរេប្រទាន

-ក្នុងករណីដែលការបើកផ្តល់បុរេប្រទានមានចំនួនច្រើនជាងអាណត្តិទូទាត់ប្រាក់បៀវត្សប្រចាំខែ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង់ប្រាក់ដែលលើសចូលរតនាគារថ្នាក់កណ្តាលនិងរតនាគាររាជធានី ខេត្តវិញ

-ក្នុងករណីដែលការបើកផ្តល់បុរេប្រទានមានចំនួនតិចជាងអាណត្តិទូទាត់ប្រាក់បៀវត្សប្រចាំខែ រតនាគារថ្នាក់កណ្តាលនិងរតនាគាររាជធានី ខេត្ត ត្រូវបើកផ្តល់ប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ ដែលខ្វះបន្ថែមជូនក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រីពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាល មេឃុំ ចៅសង្កាត់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន:</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ
- គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកសារ-កាលប្បវត្តិ